ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីជូនព័ត៌មាន

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជានៅបរទេស តែងតែយកចិត្តទុកដាក់ខ្ពស់ក្នុងការការពារផលប្រយោជន៍ពលរដ្ឋខ្មែរនៅក្រៅប្រទេស ជាអាទិ៍៖

- ជួយសម្របសម្រួលក្នុងការបញ្ជូនពលករ-ពលការិនី ទៅធ្វើការស្របច្បាប់នៅក្រៅប្រទេស។
- ចរចានិងសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសតាំងនៅ ក្នុងការផ្តល់ប័ណ្ណការងារនិងទិដ្ឋាការ/ប័ណ្ណស្នាក់នៅ ជូនពលករ-ពលការិនីខ្មែរ។
- អន្តរាគមចំពោះការរំលោភបំពានផ្សេងៗពីសំណាក់និយោជក ឬជនបរទេស មកលើពលករ-ពលការិនី ឬពលរដ្ឋខ្មែរ តាមរយៈការជួយសង្គ្រោះ ការផ្តល់ការគាំទ្រផ្នែកច្បាប់ និងការទាមទារសំណង ឬប្រាក់បៀវត្សដែលនៅសេសសល់។
- ជួយសង្គ្រោះស្ត្រីខ្មែរ ដែលរងគ្រោះចាញ់បោកមេខ្យល់ទៅរៀបការជាមួយជនបរទេស។
- ជួយឧបត្ថម្ភ និងតាមដានសុខទុក្ខរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេសដែលជួបការលំបាក ឬមានគ្រោះថ្នាក់ផ្សេងៗ និងផ្តល់ការគាំទ្រផ្នែកច្បាប់ដល់ពលរដ្ឋខ្មែរដែលត្រូវបានអាជ្ញាធរនៃប្រទេសតាំងនៅ ចោទប្រកាន់ពីការប្រព្រឹត្តបទល្មើស ឬត្រូវបានចាប់ខ្លួន និងឃុំឃាំង។
- តាមដាននិងលើកកម្ពស់ស្ថានភាពរស់នៅ ការថែទាំសុខភាព និងលក្ខខណ្ឌការងាររបស់ពលករ-ពលការិនីខ្មែរនៅក្រៅប្រទេស ដើម្បីបង្ការកុំឲ្យមានគ្រោះថ្នាក់ឬការបាត់បង់ជីវិត។
- ផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគ ព្រមទាំងរៀបចំមាតុភូមិនិវត្តន៍ជូនពលរដ្ឋ និងពលករ-ពលការិនីខ្មែរ ដែលជួបការលំបាកហើយចង់ត្រឡប់មកមាតុប្រទេសវិញ និងស្ត្រីរងគ្រោះដោយការបោកបញ្ឆោត ឬការជួញដូរផ្សេងៗ ។ល។

ជាក់ស្តែង នៅក្នុង**ឆមាសទី១ ឆ្នាំ២០១៧** នេះ (ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧) ស្ថានទូតនិងស្ថានអគ្គកុងស៊ុលកម្ពុជានៅក្រៅប្រទេស បានអន្តរាគមក្នុងការដោះស្រាយបញ្ហាជូនពលរដ្ឋ និងពលករ-ពលការិនីខ្មែរ តាមករណីដូចខាងក្រោម៖

## ១- ព្រះរាជាណាចក្រថៃ

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសថៃ និងស្ថានអគ្គកុងស៊ុលនៅខេត្តសាកែវ បាន៖

- អន្តរាគមដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន**១៧៨**នាក់ ក្នុងនោះ១៥០នាក់ ចាញ់បោកមេខ្យល់នាំទៅធ្វើការដោយខុសច្បាប់ ១៤នាក់ជាពលករដែល

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ត្រូវបានក្រុមហ៊ុនបញ្ជូនពលករបំពានកិច្ចសន្យាការងារ ៦នាក់ជាកុមាររងគ្រោះដោយការជួញដូរមនុស្ស ៤នាក់ត្រូវបាននិយោជកដកហូតលិខិតឆ្លងដែននិងមិនបើកប្រាក់ខែឲ្យ និង ៤នាក់ទៀតជាជនរងគ្រោះដោយការជួញដូរកម្លាំងពលកម្មលើទូកនេសាទ។

- អន្តរាគមដោះលែងពលរដ្ឋនិងពលករខ្មែរដែលត្រូវបានអាជ្ញាធរថៃចាប់ឃាត់ខ្លួនពីបទឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ ចំនួន៤៤៥នាក់។
- តាមដានព័ត៌មាន និងជួយសម្របសម្រួលជាមួយអាជ្ញាធរថៃ ក្នុងការរៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋ/ពលករខ្មែរដែលរស់នៅនិងធ្វើការដោយខុសច្បាប់ក្នុងប្រទេសថៃ មកកម្ពុជាវិញ តាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត ចំនួនជាមធ្យមប្រមាណពី ១០០០ ទៅ១២០០ នាក់ក្នុងមួយសប្តាហ៍។
- អន្តរាគមដោះស្រាយ និងផ្តល់ការគាំទ្រផ្នែកច្បាប់ នៅពេលមានការរំលោភបំពានផ្សេងៗពីសំណាក់និយោជកមកលើពលករខ្មែរ ព្រមទាំងទាមទារសំណងផ្សេងៗ ជូនពលករ-ពលការិនី ដែលរងការបំពាន រងរបួស ឬបាត់បង់ជីវិត ដោយសារគ្រោះថ្នាក់ការងារ។
- តាមដានសុខទុក្ខ និងជួយឧបត្ថម្ភដល់ពលរដ្ឋ/ពលករខ្មែរ ដែលជួបការលំបាក ឬមានគ្រោះថ្នាក់ផ្សេងៗ ។ល។

## ២- ប្រទេសវៀតណាម

ស្ថានឯកអគ្គរាជទូតប្រចាំនៅវៀតណាម និងស្ថានអគ្គកុងស៊ុលនៅទីក្រុងហូជីមិញ បានជួយសង្គ្រោះ និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ជូនពលរដ្ឋកម្ពុជា ចំនួន៦៨នាក់ ក្នុងនោះ៥៩នាក់រស់នៅនិងធ្វើការដោយខុសច្បាប់ ៦នាក់ជានារីរងគ្រោះដោយការជួញដូរមនុស្សឆ្លងកាត់តាមវៀតណាម និង៣នាក់ រៀបការខុសច្បាប់។

## ៣- ប្រទេសឡាវ

ស្ថានឯកអគ្គរាជទូតប្រចាំប្រទេសឡាវ និងស្ថានអគ្គកុងស៊ុលនៅទីក្រុងប៉ាក់សេ បានសម្រួលការធ្វើមាតុភូមិនិវត្តន៍ជូនពលរដ្ឋខ្មែរ ចំនួន២៤នាក់ ក្នុងនោះ១១នាក់ ចូលធ្វើការក្នុងប្រទេសឡាវដោយខុសច្បាប់ហើយត្រូវអាជ្ញាធរឡាវចាប់ខ្លួន ៩នាក់រៀបការនិងរស់នៅខុសច្បាប់ និង៤នាក់ទៀតឆ្លងដែនខុសច្បាប់ដោយខ្លួនឯងចូលប្រទេសឡាវ។

## ៤- ប្រទេសមីយ៉ាន់ម៉ា

ស្ថានឯកអគ្គរាជទូតប្រចាំប្រទេសមីយ៉ាន់ម៉ា បានសម្រួលមាតុភូមិនិវត្តន៍របស់ពលករខ្មែរចំនួន ៣នាក់ ដែលជួបការលំបាកក្នុងការងារ។

## ៥- ប្រទេសម៉ាឡេស៊ី

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសម៉ាឡេស៊ី បានជួយសង្គ្រោះ និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ជូនដល់ពលរដ្ឋនិងពលករ-ពលការិនីខ្មែរ ដែលឆ្លងដែនខុសច្បាប់ ជួបការលំបាក

ក្នុងការងារ ចាញ់បោកមេខ្យល់នាំទៅធ្វើការ និងរងគ្រោះដោយការកេងប្រវ័ញ្ចកម្លាំងពលកម្ម ពីនិយោជក ចំនួន ១៣៤នាក់ ។

**៦- ប្រទេសឥណ្ឌូណេស៊ី**

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសឥណ្ឌូណេស៊ី បានជួយសង្គ្រោះ និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ជូនពលរដ្ឋខ្មែរចំនួន **២១នាក់** ក្នុងនោះ១៩នាក់ ជាពលកររងគ្រោះដោយការជួញដូរកម្លាំងពលកម្មលើទូកនេសាទបរទេស និង២នាក់មានជម្លោះក្នុងគ្រួសារ។

**៧- ប្រទេសសិង្ហបុរី**

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសសិង្ហបុរី បានជួយសម្រួលការធ្វើមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរ ចំនួន២នាក់ ក្នុងនោះម្នាក់ជាពលករលើទូកនេសាទ និងម្នាក់ទៀត ជាពលការិនីជួបការលំបាកក្នុងការងារ។

**៨- ប្រទេសចិន**

ស្ថានឯកអគ្គរាជទូតប្រចាំនៅប្រទេសចិន ព្រមទាំងស្ថានអគ្គកុងស៊ុលកម្ពុជានានានៅទីក្រុងសៀងហៃ ទីក្រុងក្វាងចូវ ទីក្រុងណាននីង និងទីក្រុងឆុងឈីង បានជួយសង្គ្រោះ និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ជូនពលរដ្ឋខ្មែរចំនួន**២២នាក់** ដោយក្នុងនោះ ១៥នាក់ជាស្ត្រីដែលត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅរៀបការខុសច្បាប់ជាមួយបុរសចិន ៤នាក់រស់នៅមិនចុះសម្រុងជាមួយប្តីជនជាតិចិន ២នាក់ឆ្លងដែនខុសច្បាប់ និងម្នាក់មានទិដ្ឋការដែលហួសសុពលភាព។

**៩- ប្រទេសជប៉ុន**

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសជប៉ុន បានអន្តរាគមជួយទាមទារប្រាក់សំណងពីនិយោជក និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ជូនដល់កម្មសិក្សាការីខ្មែរ ចំនួន**១២** នាក់។

**១០- សាធារណរដ្ឋកូរ៉េ**

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅសាធារណរដ្ឋកូរ៉េ បាន៖

- សួរសុខទុក្ខនិងផ្សព្វផ្សាយវិធីសាស្ត្រថែទាំសុខភាពដល់ពលករ-ពលការិនីដែលបំពេញការងារនៅសាធារណរដ្ឋកូរ៉េ។
- ទាមទារប្រាក់ជានារ៉ាប់រង ជូនពលករ-ពលការិនី ដែលរងរបួស ឬបាត់បាត់ជីវិត ដោយសារគ្រោះថ្នាក់ការងារ។
- ដោះស្រាយការរំលោភបំពានផ្សេងៗពីសំណាក់និយោជក មកលើពលករខ្មែរ ។ល។

ភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៧